# RESOLUTION

## OF THE GREAT RALLY

23 FEBRUARY 2003 AT 2.00 PM
PLACE DU TRODECARO
(PARIS-FRANCE)

**MR HUN SEN/VIETNAM MUST RESPECT THE 23 OCTOBER 1991 PARIS PEACE AGREEMENT AND PUT AN END OF THE 1979-1985 TREATIES BETWEEN THE REPUBLIC POPULAR OF KAMPUCHEA AND THE REPUBLIC SOCIALIST OF VIETNAM**

# WE ARE DETERMINED TO DEFEND OUR COUNTRY

**LES JEUNES KHMERS ( L.J.K)**
**&**
**LE COMMITE DES FRONTIERES DU CAMBODGE ( CFC/CBC)**



Coordinateur - Sean Masavang

# សេចក្តីសំរេចចិត្ត នៃប្រជាពលរដ្ឋខ្មែរ នៅក្នុងពិភពលោក
## អំពីបញ្ហាបូរណភាពទឹកដី នៃប្រទេសកម្ពុជា

---

ក. *ដោយយល់ឃើញថា* ៖

(ក.១): *សន្ធិសញ្ញា សន្តិភាព មិត្តភាព និងសហប្រតិបត្តិការ* ចុះថ្ងៃទី១៨កុម្ភៈ១៩៧៩

(ក.២): *កិច្ចព្រមព្រៀង ស្តីពីតំបន់ទឹកប្រវត្តិសាស្ត្រ* ចុះថ្ងៃទី៧កក្កដា១៩៨២

(ក.៣): *កិច្ចព្រមព្រៀង ស្តីអំពីលក្ខន្តិកៈព្រំដែន* ចុះថ្ងៃទី២០កក្កដា១៩៨៣

(ក.៤): *សន្ធិសញ្ញា ស្តីពីគោលការណ៍ ដើម្បីដំណោះស្រាយព្រំដែន* ចុះថ្ងៃទី២០កក្កដា១៩៨៣

(ក.៥): *សន្ធិសញ្ញា ស្តីពីការកំណត់ព្រំដែនជាតិ* ចុះថ្ងៃ ទី២៧ធ្នូ១៩៨៥

ដែលបានចុះហត្ថលេខា រវាងសាធារណរដ្ឋសង្គមនិយមវៀតណាម(ស.ស.វ.) និងសាធារណរដ្ឋប្រជាមានិតកម្ពុជា(ស.ប.ក.) បន្ទាប់ពីកងទ័ពវៀតណាម បានចូលវាយប្រហារហើយកាន់កាប់កម្ពុជា គឺជាអំពើផ្តល់សិទ្ធិឱ្យវៀតណាម យកកម្ពុជាដាក់ក្រោម**អាណាព្យាបាលខ្លួន** **កាត់ទឹកដីកម្ពុជាឱ្យខ្លួន** និងយកកម្ពុជាជា**ដែនអាណានិគមរបស់វៀតណាម**។ អំពើខុសច្បាប់ទាំងនេះ បានធ្វើឡើង ដោយប្រមាថយ៉ាងជាក់ស្តែង លើច្បាប់អន្តរជាតិ ហើយទោះបីអង្គការសហប្រជាជាតិ (អ.ស.ប.) បានថ្កោលទោស ជាបន្តបន្ទាប់ក្តី។

ខ. ***ដោយបានដឹងច្បាស់ថា*** បន្ទាប់ពីការអនុវត្តិន៍ សេរីវៃខ្សែបន្ទាត់ព្រំដែនខ្មែរ និងការកាត់ផ្តាច់ដីខ្មែរឱ្យវៀតណាម ចាប់តាំងពីឆ្នាំ១៩៧៩មក ជាមួយគ្នានិងការបញ្ចូលឥតឈប់ឈរ នូវជួរក្រុមអាណិកជនវៀតណាម មកតាំងទីនៅតាមចិត្តនៅកម្ពុជា (មានចំនួនច្រើនលាននាក់ហើយ នៅពេលនេះ) នៅតាមព្រំដែនខាងខ្មែរ និងតាមតំបន់សំបូរភោគទ្រព្យ ហើយនិងតាមទីសំខាន់ៗក្នុងស្រុក វាបានបណ្តាលឱ្យប្រជាពលរដ្ឋខ្មែរ នៅទីកន្លែងទាំងនោះ ទទួលទុក្ខវេទនាជាខ្លាំង ដោយត្រូវបាត់បង់សម្បត្តិកម្មសិទ្ធិខ្លួន បាត់បង់សិទ្ធិសេរីភាពខ្លួន ឬត្រូវវៀតណាមបបង្ខំ ឱ្យបោះបង់សញ្ជាតិខ្លួនជាខ្មែរ (បើខ្លួនចង់រស់នៅ លើដីធ្លីដូនតារបស់ខ្លួន តទៅទៀត) គឺជាហេតុបានធ្វើឱ្យខូចយ៉ាងធ្ងន់ធ្ងរ ដល់សណ្តាប់ធ្នាប់នៃសង្គមខ្មែរ និងក្នុងសេដ្ឋកិច្ចខ្មែរ ហើយបានក្លាយជា**គ្រោះថ្នាក់យ៉ាងធំ ដល់ឯកភាពជាតិ** របស់ខ្មែរ។

គ. ***ដោយបានដឹងច្បាស់***ទៀតថា នៅខាងដែនសមុទ្រវិញ *"កិច្ចព្រមព្រៀង ស្តីពីតំបន់ទឹកប្រវត្តិសាស្ត្រ"* ចុះថ្ងៃទី៧កក្កដា១៩៨២ (ក.២) គឺជាអំពើ ដែលសាធារណរដ្ឋប្រជាមានិតកម្ពុជា បាន**កាត់ផ្ទៃសមុទ្រខ្មែរ**មួយភាគធំធេង ឱ្យវៀតណាម ហើយដើម្បីឱ្យប្រទេសឯទៀតទទួលស្គាល់ វៀតណាមបានធ្វើសេចក្តីប្រកាស់មួយភ្លាម នាថ្ងៃ១២វិច្ឆិកា១៩៨២ ដល់មហាសន្និបាតនៃអ.ស.ប. អំពី"ខ្សែបន្ទាត់មូលដ្ឋាន"ថ្មី នៃដែនសមុទ្រ

របស់គេ រួចធ្វើសេចក្ដីប្រកាស់មួយទៀត នាថ្ងៃ៥មិថុនា១៩៨៤ អំពីដែនអាកាសថ្មីរបស់គេ ដែលសុទ្ធជាផល់កើតបាន ពី"*កិច្ចព្រមព្រៀង*"(ក.២) ជាមួយស.ប.ក.នោះ។

ឃ. ***ដោយយល់ឃើញថា*** ជាអំពើរំលោភច្បាប់យ៉ាងច្បាស់ និងមិនអាចទទួលបានទៀត ហេតុដែលសាធារណរដ្ឋសង្គមនិយមវៀតណាម បានចុះហត្ថលេខាម្នាក់ឯង ជាមួយរាជាណាចក្រថៃឡង់ នាថ្ងៃទី១១សីហា ១៩៩៧ លើកិច្ចព្រមព្រៀងទ្វេភាគីមួយ - ដោយយកជាមូលដ្ឋាន នូវ*កិច្ចព្រមព្រៀង ស្ដីពីតំបន់ទឹកសមុទ្រ ប្រវត្តិសាស្ត្រ នាថ្ងៃទី៧កក្កដា១៩៨២*(ក.២) ជាមួយស.ប.ក.ហ្នឹង - ដើម្បីកំណត់ព្រំដែនសមុទ្រគេទាំងពីរ ជាថ្មី ដោយជាន់**លើសិទ្ធិរបស់កម្ពុជា** ដែលជាប្រទេសមានភាគចំណែក នៅលើផ្ទៃសមុទ្រនៅទីនោះដែរ។

ង. ***ដោយយល់ឃើញថា*** ជាអំពើរំលោភទាំងស្រុង ដែល"គណៈកម្មការចំរុះខ្មែរ-វៀតណាម" បានយកសន្ធិសញ្ញា និងកិច្ចព្រមព្រៀងខុសច្បាប់ នាឆ្នាំ១៩៨៣និង១៩៨៥នោះ ជាមូលដ្ឋាននៃការចរចាបន្ត និងការបង្កើតគំរោង"**សន្ធិសញ្ញាបន្ថែម**" ដើម្បីកំណត់ជាក់ស្ដែងជាថ្មី នូវបន្ទាត់ព្រំដែន រវាងវៀតណាមនិងព្រះរាជាណាចក្រកម្ពុជា នៅក្នុងបំណងច្បាស់ ឱ្យព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ជាមួយគ្នាតែម្ដង នៅពេលនេះ នូវសន្ធិសញ្ញានិងកិច្ចព្រមព្រៀង ដែលវៀតណាម និងសាធារណរដ្ឋប្រជាមានិតកម្ពុជា បានធ្វើខុសច្បាប់អន្តរជាតិ នាឆ្នាំ១៩៧៩ ១៩៨២ ១៩៨៣ និង១៩៨៥ នោះ។

ច. ***ដោយយល់ឃើញថា*** កិច្ចព្រមព្រៀងសន្តិភាពស្ដីពីកម្ពុជា នាក្រុងប៉ារីសឆ្នាំ១៩៩១ ព្រមទាំងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា(មាត្រា៥៥) បានថ្កោលទោសយ៉ាងច្បាស់ លើសន្ធិសញ្ញាទាំងអស់ ដែលបំផ្លាញអធិបតេយ្យ ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាននៃទឹកដី ឯកភាពជាតិ របស់កម្ពុជា តួយ៉ាងដូចសន្ធិសញ្ញានិងកិច្ចព្រមព្រៀង រវាងវៀតណាមនិងសាធារណរដ្ឋប្រជាមានិតកម្ពុជា ខាងលើនោះ។

ឆ. ***ដោយយល់ឃើញថា*** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (មាត្រា៩២) បានហាមយ៉ាងច្បាស់ មិនឱ្យរដ្ឋសភាកម្ពុជា អនុម័តច្បាប់-សន្ធិសញ្ញា ដែលផ្ទុយនិងគោលការណ៍ នៃការថែរក្សានិងការពារ អធិបតេយ្យ ឯករាជ្យ បូរណភាពនិងភាពមិនអាចរំលោភបាននៃទឹកដី និងឯកភាពជាតិ របស់កម្ពុជា។

ជ. ***ដោយរំលឹកថា*** សំបុត្រចុះថ្ងៃទី១កក្កដា២០០២ របស់លោក*ហាន់ស៍-កូរ៉េល* (អគ្គលេខាធិការរង នៃ អ.ស.ប. មកជូន*គណៈកម្មាធិការព្រំដែនកម្ពុជា*(CFC) នៅប្រទេសបារាំង ហើយដោយបានចម្លងផ្ញើរឱ្យរាជ-រដ្ឋាភិបាលកម្ពុជាផង គឺជាការបញ្ជាក់ថា អង្គការពិភពលោកនេះ បានយល់ច្បាស់ ចំពោះគ្រោះថ្នាក់ដ៏ធំនៃអំពើរំលោភនានារបស់វៀតណាម តាមបែបបទផ្សេងៗ មកលើសិទ្ធិជាតិរបស់កម្ពុជា ហើយបានរំលឹកផងទៀត នូវ**កិច្ចសន្យារបស់កម្ពុជា** ក្នុងកិច្ចព្រមព្រៀងក្រុងប៉ារីសឆ្នាំ១៩៩១ ថា"បញ្ចប់សន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយណា ដែលមិនស្របទៅនឹង *អធិបតេយ្យ ឯករាជ្យ បូរណភាពនិងភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រិតភាព និងឯកភាពជាតិ របស់កម្ពុជា*"។

ឈ. ***ដោយរំលឹកផងថា*** ដោយហេតុមានសម្បជញ្ញៈច្បាស់ ចំពោះគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរ មកលើបូរណភាពទឹកដី អធិបតេយ្យ និងជាពិសេស ចំពោះ**លក្ខន្តិកៈនិងជំហររបស់កម្ពុជា** នៅលើផ្ទៃអន្តរជាតិ ប្រជាពលរដ្ឋខ្មែរគ្រប់លក្ខខ័ណ្ឌ នៅកម្ពុជានិងនៅក្នុងពិភពលោក បានធ្វើបាតុកម្មផ្សេងៗ ឥតឈប់ឈរ ជាច្រើនឆ្នាំមក ហើយ ថ្កោលទោសយ៉ាងខ្លាំងក្លា លើសន្ធិសញ្ញានិងកិច្ចព្រមព្រៀងខាងលើ រវាងវៀតណាម និងសាធា-រណរដ្ឋប្រជាមានិតកម្ពុជា ហើយបានស្នើររាល់ពេល សុំឱ្យលោកហ៊ុន-សែន នាយករាជរដ្ឋាភិបាលកម្ពុជា ប្រកាស់ជាឯកតោភាគី នូវមោឃៈភាពរបស់វា (ស្របតាមបទបញ្ញា នៃកិច្ចព្រមព្រៀងសន្តិភាព នៅក្រុងប៉ារីស និងបទបញ្ញានៃរដ្ឋធម្មនុញ្ញកម្ពុជាផង) ប៉ុន្តែ**ឥតបានផល់អ្វីសោះឡើយ** ពីនាយករាជរដ្ឋាភិបាលនោះ។

ញ. ***ដោយបានឃើញច្បាស់នៅទីបំផុតថា*** រាជរដ្ឋាភិបាលនៃលោកហ៊ុន-សែន និងអ្នកតំណាងខ្លួន នៅ តចចេសដោយឥតអៀនខ្មាស់ **ធ្វើការពន្យល់មួលកាច់ផ្លេសផ្លាស់ និងភរភូតបញ្ឆោតប្រជាជនខ្មែរ** អំពិអត្ថន័យពិត និងការអនុវត្តន៍ជាក់ស្តែង តាំងពីឆ្នាំ១៩៧៩មក នៃសន្ធិសញ្ញានិងកិច្ចព្រមព្រៀងខាងលើ ដែលបានបំផ្លាញយ៉ាងធ្ងន់ធ្ងរ ដល់ប្រទេសកម្ពុជា និង ដល់ប្រយោជន៍ប្រជាពលរដ្ឋខ្មែរ។

***យើងខ្ញុំ ជាតំណាងប្រជាពលរដ្ឋខ្មែរ*** *នៅប្រទេសបារាំង អង់គ្លេស បែលហ្ស៊ិក ហុលឡង់ អាល្លឺម៉ាញ អូទ្រីស អ៊ីតាលី ស្វីស សហរដ្ឋអាមេរិក កាណាដា អូស្ត្រាលី កម្ពុជា ប្រជុំគ្នាក្នុងមហាបាតុកម្មជាសាធារណៈ នៅក្រុងប៉ារីស រៀបចំដោយ "គណៈ កម្មាធិការព្រំដែនកម្ពុជា" និងសមាគម"យុវជនខ្មែរ" នាថ្ងៃ២៣កុម្ភៈ២០០៣នេះ សំរេចចិត្តរួមគ្នា* ***ប្រកាស់ ជាឯកច្ឆន្ទ*** *ថា ៖*

១. *ក្នុងនាមប្រជាពលរដ្ឋខ្មែរ* ដែលជា*ម្ចាស់វាសនា នៃប្រទេសជាតិរបស់ខ្លួន និងជាម្ចាស់ដើមនៃអំណាចទាំងអស់* ប្រកាសជាឧឡារិកនៅថ្ងៃនេះ នូវ**មោឃភាព** និង**អធរមានទាំងស្រុង** នៃសន្ធិសញ្ញានិងកិច្ចព្រម-ព្រៀង នាឆ្នាំ១៩៧៩ ១៩៨២ ១៩៨៣ ១៩៨៥ រវាងសាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋប្រជាមានិតកម្ពុជា ព្រមទាំងកិច្ចការទាំងអស់ របស់"*គណៈកម្មការចំរុះខ្មែរ-វៀតណាម*" ដែលបានយកសន្ធិសញ្ញា និងកិច្ចព្រមព្រៀងខុសច្បាប់នេះ ធ្វើជាមូលដ្ឋាន ហើយនិងធ្វើគំរោង"សន្ធិសញ្ញាបន្ថែម"។

២. ***ប្ដឹងជំទាស់ដាច់ខាត*** ដល់ប្រទេសនានា និងអ.ស.ប. អំពីកិច្ចព្រមព្រៀងទ្វេភាគី នាថ្ងៃទី១១សីហា ១៩៩៧ រវាងសាធារណរដ្ឋសង្គមនិយមវៀតណាម និងរាជាណាចក្រថៃឡង់ ដើម្បីកំណត់ដែនសមុទ្រគេជាថ្មី ដោយរំលោភជាក់ស្តែង លើដែនសមុទ្ររបស់កម្ពុជា។

៣. ***ថ្កោលទោសយ៉ាងខ្លាំង*** ដល់អំពើរំលោភអំណាចជាថ្មីទៀត នៃលោកហ៊ុន-សែន នាយករាជរដ្ឋាភិបាល ដែលបានសំរេចយក និងគ្រោងចុះហត្ថលេខា នាខែមីនា២០០៣នេះ នូវគំរោង"សន្ធិសញ្ញាបន្ថែម" ដើម្បីជាការបញ្ជាក់ នៃអំពើកាត់ដែនដីគោកខ្មែរ និងដែនសមុទ្រខ្មែរ ដែលលោកបានធ្វើ **ពីពេលមុននិងពេលនេះ** ឱ្យទៅសាធារណរដ្ឋសង្គមនិយមវៀតណាម។

៤. ***សុំអញ្ជើញអ្នកតំណាងរាស្ត្រខ្មែរ*** ធ្វើការបង្កនិតិវិធីជាបន្ទាន់ ឱ្យរដ្ឋសភាកម្ពុជា **ប្រកាសមិនទទួលស្គាល់**សន្ធិសញ្ញានិងកិច្ចព្រមព្រៀង នាឆ្នាំ១៩៧៩ ១៩៨២ ១៩៨៣ ១៩៨៥ និងផលវិបាករបស់វាទាំងអស់ រវាងសាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋប្រជាមានិតកម្ពុជា ឱ្យស្របតាមកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ស្តីពីកម្ពុជាឆ្នាំ១៩៩១ ព្រមទាំងរដ្ឋធមនុញ្ញ(មាត្រា៥៥) នៃព្រះរាជាណាចក្រកម្ពុជា។

៥. ***ទូលសុំសម្តេច នរោត្តម-រណឫទ្ធិ*** ប្រធានរដ្ឋសភា ដោយយោងតាមស្មារតី នៃរដ្ឋធមនុញ្ញនៃព្រះរាជា-ណាចក្រ (មាត្រា៥៥និងមាត្រា៩២) ទ្រង់ប្រកែកជាពិសេស **មិនឱ្យរដ្ឋសភាទទួលពិនិត្យ** គំរោង"សន្ធិសញ្ញាបន្ថែម" ដែលបានធ្វើនៅលើមូលដ្ឋានខុសច្បាប់ ដោយរាជរដ្ឋាភិបាលកម្ពុជា ជាមួយរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម។

៦. *ទូលសុំដោយសេចក្តីគោរពបំផុត* ព្រះមហាក្សត្រ ព្រះបាទនរោត្តម-សីហនុ ទ្រង់ព្រះមេត្តាដ៏ខ្ពង់ខ្ពស់ តំរូវឱ្យរាជរដ្ឋាភិបាល និងរដ្ឋសភានៃព្រះរាជាណាចក្រ គោរពនិងអនុវត្តិមត់ចត់ នូវកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសឆ្នាំ១៩៩១ និងបទបញ្ញាកាតព្វកិច្ច នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ។

៧. *ទូលសុំដែងជាថ្មីទៀត* នូវការគាំទ្រ ដោយសេចក្តីគោរពកោតដ៏ជ្រាលជ្រៅ នឹងដោយមានមោទនភាពជាខ្លាំង ដល់ព្រះរាជឆន្ទៈ**ស្នេហាជាតិដ៏ខ្ពង់ខ្ពស់** នៃព្រះមហាក្សត្រ ព្រះបាទនរោត្តម-សីហនុ ដែលព្រះអង្គប្តេជ្ញា ដូចក្នុងអតីតកាល **មិនទទួលស្គាល់** សន្ធិសញ្ញានិងកិច្ចព្រមព្រៀងខុសច្បាប់ រវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម និងគំរោង"សន្ធិសញ្ញាបន្ថែម" ដែលរាជរដ្ឋាភិបាលរបស់លោកហ៊ុន-សែនពេលនេះ បានធ្វើឡើង ជាមួយរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

៨. *សុំអញ្ជើញ*លោកអគ្គលេខាធិការ នៃអង្គការសហប្រជាជាតិ និងលោកនាយករដ្ឋាភិបាល ប្រទេសបារាំង និងប្រទេសឥណ្ឌូនេស៊ី -ជាសហប្រធាន នៃសន្និសិទសន្តិភាពស្តីពីកម្ពុជា នាក្រុងប៉ារីសឆ្នាំ១៩៩១)- មេត្តាធ្វើសេចក្តីរំលឹក ដល់ប្រទេសដែលបានចុះហត្ថលេខា លើកិច្ចព្រមព្រៀងក្រុងប៉ារីសនោះ ជាពិសេសគឺប្រទេសវៀតណាម ថៃឡង់ និងកម្ពុជា អំពីកិច្ចសន្យាយ៉ាងឱឡារិករៀងខ្លួន ថា**ទទួលស្គាល់និងគោរព** *បូរណភាព និងភាពមិនអាចរំលោភបាន នៃដែនដីរបស់កម្ពុជា* ហើយរំលឹកជាថ្មីទៀត នូវ**កិច្ចសន្យារបស់កម្ពុជា** ឱ្យរដ្ឋាភិបាលកម្ពុជា ធ្វើការ"បញ្ចប់"សន្ធិសញ្ញានិងកិច្ចព្រមព្រៀង រវាង*អតីត*សាធារណរដ្ឋប្រជា-មានិតកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលពិតជាមិនស្របទៅនិង *អធិបតេយ្យ ឯករាជ្យ បូរណភាពនិងភាពមិនអាចរំលោភ បាននៃដែនដី អព្យាក្រិតភាព និងឯកភាពជាតិ* របស់ប្រទេសកម្ពុជាទេ។

---

**យើងខ្ញុំ** សូមឱ្យលោកប្រធាន នៃ«គណៈកម្មាធិការព្រំដែនកម្ពុជា» ទទួលបន្ទុក

*-ទូលថ្វាយសេចក្តីសំរេចចិត្តរួមគ្នានេះ ចំពោះព្រះមហាក្សត្រ ព្រះបាទនរោត្តម-សីហនុ សូមទ្រង់ជ្រាប។*

និងផ្ញើរថ្វាយនិងជូន ដើម្បីជាការអនុវត្តន៍សិទ្ធិ របស់យើងខ្ញុំ ចំពោះ ៖

*-សម្តេចនរោត្តម-រណឫទ្ធិ៍ ប្រធានរដ្ឋសភា។*

*-ព្រះអង្គម្ចាស់ និងលោកស្រី-លោក ជាប្រធាននិងជាសមាជិក នៃរដ្ឋសភា និងព្រឹទ្ធសភា។*

*-ព្រះអង្គម្ចាស់ និងលោកស្រី-លោក ជាប្រធាននិងជាសមាជិក នៃក្រុមប្រឹក្សាធម្មនុញ្ញ។*

*-លោកនាយករាជរដ្ឋាភិបាល ហ៊ុន-សែន។*

*-លោកអគ្គលេខាធិការ នៃអង្គការសហប្រជាជាតិ។*

*-លោកស្រីនិងលោកសហប្រធាន នៃសន្និសិទ្ធក្រុងប៉ារីសស្តីពីកម្ពុជា។*

*-រដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ។*

*-រដ្ឋាភិបាលនៃប្រទេសនានា ជាហត្ថលេខី លើកិច្ចព្រមព្រៀងក្រុងប៉ារីស។*

ធ្វើនៅក្រុងប៉ារីស (ប្រទេសបារាំង) ថ្ងៃទី២៣កុម្ភៈ២០០៣

*ប្រធាន សមាគម"យុវជនខ្មែរ"(ប្រទេសបារាំង)* | *ប្រធាន គណៈកម្មាធិការព្រំដែនកម្ពុជា*

*(ហត្ថលេខា)* **វង-បូរិន** | *(ហត្ថលេខា)* **ស៊ាន-ប៉េងសែ**

[Original text: *French*]

# RESOLUTION OF THE CAMBODIAN CITIZENS IN THE WORLD
## ON THE QUESTION OF CAMBODIA'S BORDERS

**A.** ***Considering that:***
(A.1)*: The Treaty of Peace, Friendship and Co-operation* of February 18**,** 1979,
(A.2)*: The Agreement on the Zone of Historical Water* of July 7, 1982,
(A.3)*: The Agreement on the Border Statute* of July 20, 1983,
(A.4)*: The Treaty on the Principle for Settlment of Border Disputes* of July 20, 1983,
(A.5)*: The Treaty on the National Border Delimitation* of December 27, 1985,
concluded between the Socialist Republic of Vietnam (SRV) and the so called People's Republic of Kampuchea (PRK) following the invasion and during the military occupation of Cambodia by Vietnam, were in fact ACTS OF PROTECTORATE, OF TERRITORIES ANNEXATION and OF COLONIZATION IMPOSED ON CAMBODIA BY VIETNAM, illegal acts made with the obvious contempt of the International law, and in spite of several renewed judgment of the UN;

**B.** ***Knowing that*** the application in fact since 1979 of these treaties and agreements, forcing the revision of the delimitation of the land border, the annexations of Cambodian territories to Vietnam, at the same time as the colonization of Cambodia by continual flows of Vietnamese immigrants (several million people now) in the border areas and in the rich and sensitive zones inside the country, inflicting the Cambodian populations in these places the dramatic losses of their properties, their rights and freedoms, if not even their nationality of origin (if they want to remain on their ancestral lands), causing consequently serious disorders in the Cambodian society and the economy, and constituting a great danger to **the national unity** of Cambodia;

**C.** ***Knowing also that***, in the maritime area, the Agreement of July 7, 1982 (A.2) was in fact an instrument of transfer by the PRK a significant sea area of Cambodia for the profit of the SRV which, immediately, deposited at the General assembly of the United Nations on 12 November 1982 a declaration asking all countries to respect the new base lines of its Water, and on June 5, 1984 its new airspace, both acquired under the terms of the same Agreement (A.2);

**D.** ***Regarding*** as abusive and unacceptable act the fact that the Socialist Republic of Vietnam (SRV), while being based on the same Agreement with the PRK of July 7, 1982, concluded with Thailand a Bilateral agreement on August 11, 1997 to fix their respective maritime zones, and this, while deliberately encroaching on the basic right of Cambodia as third country partially included in the maritime area in question;

**E.** ***Regarding*** as completely abusive the development based on the said treaties of 1983 and 1985 the project of an "Additive Treaty" by the current "Khmer-Vietnamese Mixed Commission" to materialize the work of border delimitation between Vietnam and the Kingdom of Cambodia, at the same time, to reconfirm by the latter (Cambodia) those illegal treaties and agreements between the SRV and the PRK;

**F.** ***Considering*** the formal judgment of the Paris Peace Agreements of 1991 on Cambodia and the Constitution of Cambodia (Article 55) on the treaties and agreements destroying its territorial sovereignty, its independence, its integrity and inviolability, its national unity, whose the aforesaid treaties and agreements between the RSV and the RPK certainly become a part of them;

**G.** ***Considering*** that article 92 of the Constitution of Cambodia defends the National Assembly of Cambodia to adopt any contrary law with the principles of conservation and the defense of independence, sovereignty, territorial integrity, and national unity of Cambodia;

**H.** ***Recalling*** that the response of last July 1, the 2002 to the Cambodia's Borders Committee (CBC) from Mr. Hans Corell, Under-Secretary General of UN – with communication to the Cambodian Royal Government - shows clearly that this world organization is conscious of the danger of continuous violations by Vietnam, in various forms, of Cambodia's national rights, and recalls Cambodia its commitment to the Paris Peace Agreements of 1991 "*to terminate all treaties and agreements which are incompatible with its territorial sovereignty, its independence, its integrity and inviolability, its neutrality and its national unity* ";

**I.** ***Recalling also*** that, conscious of the imminent danger that Cambodia incurs for its territorial integrity, its sovereignty and in particular **its statute and its position on the international level**, Cambodian Citizens of all walks of life in Cambodia and around the World have constantly expressed, for several years, their vigorous judgment of these treaties and agreements between the SRV and the PRK and have asked, on several occasions, *in vain*, Mr. HUN SEN, head of the Cambodian Government, to unilaterally denounce them under the terms of the Paris Peace Agreements of 1991 on Cambodia and under the provisions of the Constitution of the Kingdom of Cambodia;

**J**. ***Noting finally*** that the Government of Mr. Hun Sèn and his representatives shamefully persist to give misleading interpretations and to lie Cambodian people the terms of the aforesaid treaties and agreements and the consequences of their application since 1979, with the very serious detriments to Cambodia and its People's interests;

**WE,**
*REPRESENTATIVES OF THE CAMBODIAN CITIZENS RESIDING IN FRANCE, IN THE UNITED KINGDOM, IN BELGIUM, IN HOLLAND, IN GERMANY, IN AUSTRIA, IN ITALY, IN SWITZERLAND, IN U.S.A, IN CANADA, IN AUSTRALIA, IN CAMBODIA JOINED TOGETHER IN A COMMON AND PUBLIC DEMONSTRATION ORGANIZED IN PARIS, FRANCE, ON FEBRUARY 23,2003, BY "THE CAMBODIA'BORDERS COMMITTEE" AND "THE YOUNG CAMBODIAN PEOPLE"ASSOCIATION,*
BY THE PRESENT RESOLUTION,

**1. On behalf of the Cambodian people**, *Master of their country's Destiny and first Holders of all capacities*,
**We solemnly declare NULL AND VOID** the treaties and agreements between the Socialist Republic of Vietnam (SRV) and the so-called People's Republic of Kampuchea (PRK) of 1979, 1982, 1983 and 1985 mentioned above, as well as the work of the "Khmer-Vietnamese Mixed Commission" which results from them;

**2. We strongly denounce** to the interested States and the UN the treaty of August 11, 1997 concluded between Vietnam and Thailand, delimiting their new maritime area, based on the July 7, 1982's agreement between the SRV and the PRK, seriously encroaching the maritime area of Cambodia;

**3. We vigorously condemn** Mr. Hun Sen, head of the royal Government, for his new power abuse to sign the project of an "**Additive Treaty**" next March, to confirm its old and new

transfers of the Cambodian lands and maritime area to the Socialist Republic of Vietnam;

4. **We demand** the Cambodian parliamentary members to immediately initiate a procedure of Declaration by the National Assembly of NON-RECOGNITION of the treaties and agreements of 1979, 1982, 1983, 1985, between the SRV and the PRK and all their effects, in accordance with the Paris Peace Agreements of 1991 on Cambodia, and with Article 55 of the Constitution of the Kingdom of Cambodia;

5. **We demand** the President of the National Assembly, prince Norodom Ranariddh, under the terms of articles 55 and 92 of the Kingdom's Constitution, to oppose an **exception of inadmissibility** to the project of the "Additive Treaty" elaborated on illegal bases by the royal Government and the government of the Socialist Republic of Vietnam;

6. **We respectfully ask** His Majesty The King Preah Bat Norodom Sihanouk to condescend on taking care of the strict application by the royal Government and the Parliament of Cambodia of the Paris Peace Agreements of 1991 and of the peremptory provisions of the Kingdom's Constitution;

7. **We strongly support** with admiration and great pride the High patriotic decision of His Majesty the King for not recognizing, as in the past, the illegal Treaties and Agreements between the Socialist Republic of Vietnam and the so-called People's Republic of Kampuchea, nor, today, the project of the "Additive Treaty" prepared by Mr. Hun Sen's current Government and the Socialist Republic of Vietnam;

8. **We request** the Secretary-general of the United Nations, as well as the Governments of France and Indonesia, Co-Presidents of the Paris Peace Conference of 1991, to recall the signatory Governments of the Agreements resulting from this Conference, in particular Vietnam, Thailand and Cambodia, their commitments **to respect the territorial integrity and the territorial inviolability of Cambodia**, as well as the Cambodia's commitment to terminate these treaties and agreements between the SRV and the PRK which are absolutely incompatible with Cambodia's sovereignty, independence, neutrality, territorial integrity and inviolability, and national unity.

---

The president of the "Cambodia Borders Committee" is in charge to submit the present Resolution
*- to the High knowledge of His Majesty the King NORODOM SIHANOUK,*
and to transmit it, for continuations of our rights,
*- to Prince NORODOM RANARIDDH, President of the National Assembly,*
*- to the President and the Members of the National Assembly and the Senate,*
*- to the President and the Members of the Constitutional Council,*
*- to Mr. HUN SEN, Prime Minister,*
*- to Mr. the Secretary-general of the UN,*
*- to Madam and Mr. Co-p residents of the Paris Peace Conference on Cambodia,*
*- to the Government of the Socialist Republic of Vietnam and to the Government of the Kingdom of Thailand,*
*- to other signatory Governments of the Paris Peace Agreements on Cambodia.*

*DONE IN PARIS (FRANCE), FEBRUARY 23, 2003*

The President
Association of "Young Cambodian People",

*(Signature)* VORGN BORIN

The President
"Cambodia's Borders Committee",

*(Signature)* SEAN PENGSÈ

# RÉSOLUTION DES CITOYENS CAMBODGIENS DU MONDE
## SUR LA QUESTION DES FRONTIÈRES DU CAMBODGE

***Texte d'origine : français***

**A.** ***Considérant que*** :
(A.1) *: Le Traité de Paix, d'Amitié et de Coopération*, du 18 février 1979,
(A.2) *: L'Accord sur la Zone des Eaux Historiques*, du 7 juillet 1982,
(A.3) *: L'Accord sur le Statut Frontalier*, du 20 juillet 1983,
(A.4) *: Le Traité sur le Principe de la Résolution des Questions de Frontières*, du 20 juillet 1983,
(A.5) *: Le Traité sur la Délimitation de la Frontière*, du 27 décembre 1985,
conclus entre la République Socialiste du Vietnam (RSV) et la dénommée République Populaire du Kampuchéa (RPK) à la suite de l'invasion et pendant l'occupation militaire du Cambodge par le Vietnam, constituent en fait des ACTES DE PROTECTORAT, d'ANNEXION DE TERRITOIRES et de COLONISATION IMPOSÉS AU CAMBODGE PAR LE VIETNAM, actes illégaux commis au mépris flagrant du Droit international, et malgré la condamnation plusieurs fois renouvelée de l'ONU ;

**B.** ***Sachant que*** l'application de fait depuis 1979 de ces traités et accords, forçant la révision de la délimitation de la frontière terrestre, les annexions au Vietnam de territoires cambodgiens, en même temps que la colonisation du Cambodge par des flots incessants d'immigrés vietnamiens (de plusieurs millions de personnes à présent) dans les régions frontalières et dans les zones riches et sensibles à l'intérieur du pays, infligeant aux populations cambodgiennes de ces lieux des pertes dramatiques de leurs propriétés, de leurs droits et libertés, sinon de leur nationalité d'origine même (s'ils veuillent demeurer sur leurs terres ancestrales), causant en conséquence de graves désordres dans la société et l'économie cambodgiennes et constituant un grand danger pour **l'unité nationale** du Cambodge ;

**C.** ***Sachant, d'autre part, que*** dans le domaine maritime, l'Accord du 7 juillet 1982 (A.2) est de fait un acte de cession par la RPK d'importantes étendues d'Eaux territoriales cambodgiennes au profit de la RSV lequel, immédiatement, a déposé à l'Assemblée Générale de l'Organisation des Nations Unies le 12 novembre 1982 une déclaration demandant à tous les pays de respecter les nouvelles lignes de base de ses Eaux, et le 5 juin 1984 son nouvel espace aérien, tous les deux acquis en vertu du même Accord (A.2) ;

**D.** ***Considérant*** comme acte abusif et inacceptable le fait que la République Socialiste du Vietnam (RSV), en se basant sur le même Accord du 7 juillet 1982, a conclu avec la Thaïlande l'Accord bilatéral du 11 août 1997 pour fixer les zones maritimes respectives de ces deux pays, et ce, en empiétant délibérément sur le droit fondamental du Cambodge en tant que pays tiers inclus partiellement dans l'espace maritime en cause ;

**E.** ***Considérant*** comme totalement abusive l'élaboration basée sur lesdits traités de 1983 et 1985 du projet de «Traité Additif» par l'actuelle Commission Mixte Khméro-Vietnamienne pour matérialiser effectivement les travaux de délimitation des frontières entre le Vietnam et le Royaume du Cambodge et, en même temps, faire confirmer par ce dernier ces traités et accords illégaux entre la RSV et la RPK ;

**F.** ***Considérant*** la condamnation formelle par les Accords de Paix de Paris de 1991 sur le Cambodge et par la Constitution du Cambodge (Article 55) des traités et accords détruisant sa souveraineté, son indépendance, son intégrité et son inviolabilité territoriales, son unité nationale, dont lesdits traités et accords entre la RSV et la RPK en font bien partie ;

**G.** ***Considérant*** que l'article 92 de la Constitution du Cambodge défend l'Assemblée nationale du Cambodge d'adopter toute loi contraire aux principes de préservation et de défense de l'indépendance, de la souveraineté, de l'intégrité territoriale, de l'unité nationale du Cambodge

**H.** ***Rappelant*** que la réponse du 1[er] juillet 2002 dernier au Comité des Frontières du Cambodge (CFC) de M. Hans Corell, Secrétaire Général-adjoint de l'Onu – avec communication au Gouvernement royal cambodgien - montre clairement que cet organisme mondial est conscient du danger des violations continues, sous diverses formes, par le Vietnam, des droits nationaux du Cambodge, et rappelle le Cambodge son engagement dans les Accords de Paris de 1991 de *"mettre fin aux traités et accords qui sont incompatibles avec sa souveraineté, son indépendance, son intégrité et son inviolabilité territoriales, sa neutralité et son unité nationale"* ;

**I.** ***Rappelant que***, conscients du danger imminent qu'encourt le Cambodge, pour son intégrité territoriale, sa souveraineté et en particulier son statut et sa position sur le plan international, les Citoyens cambodgiens de toutes conditions sociales au Cambodge et dans le Monde ont manifesté sans cesse, depuis plusieurs années, leur vigoureuse condamnation de ces traités et accords entre la RSV et la RPK et ont demandé, à plusieurs reprises, *en vain*, à Monsieur HUN SEN, chef du Gouvernement du Cambodge, de les dénoncer unilatéralement en vertu des Accords de Paix de Paris de 1991 sur le Cambodge et des dispositions de la Constitution du Royaume du Cambodge ;

**J**. ***Constatant enfin*** que le Gouvernement de M. Hun Sèn et ses représentants persistent honteusement à donner des interprétations fallacieuses et à mentir au Peuple Cambodgien sur les termes desdits traités et accords et les conséquences réelles de leur application depuis 1979, aux très graves détriments du Cambodge et de son Peuple ;

**NOUS,**
*REPRÉSENTANTS DES CITOYENS CAMBODGIENS RÉSIDANT EN FRANCE, AU ROYAUME-UNI, EN BELGIQUE, EN HOLLANDE, EN ALLEMAGNE, EN AUTRICHE, EN SUISSE, EN ITALIE, EN AMERIQUE, AU CANADA, EN AUSTRALIE, AU CAMBODGE*
*RÉUNIS DANS UNE MANIFESTATION COMMUNE ET PUBLIQUE ORGANISÉE À PARIS, FRANCE, CE 23 FEVRIER 2003, PAR «LE COMITÉ DES FRONTIÈRES DU CAMBODGE» ET «LES JEUNES CAMBODGIENS»,*
**PAR LA PRÉSENTE RÉSOLUTION,**

**1. Au nom du Peuple Cambodgien**, *Maître du Destin de son pays et Détenteur originaire de tous les pouvoirs*,
**Déclarons** solennellement NULS ET NON AVENUS les traités et accords entre la République Socialiste du Vietnam (RSV) et la dénommée République Populaire du Kampuchéa (RPK) de 1979, 1982, 1983 et 1985 ci-dessus signalés, ainsi que les travaux de la Commission Mixte Khméro-Vietnamienne qui en découlent ;

**2. Dénonçons** vivement auprès des Etats intéressés et de l'ONU le traité du 11 août 1997 conclu entre le Vietnam et la Thaïlande délimitant leurs nouveaux domaines maritimes comme étant la consécration de l'accord du 7 juillet 1982 entre la RSV et la RPK et empiétant gravement le domaine maritime du Cambodge ;

**3. Condamnons** vigoureusement le nouvel abus de pouvoir de M. Hun Sèn, chef du Gouvernement royal prévoyant sa signature en mars prochain du projet de «Traité additif», pour

confirmer ses anciennes et nouvelles cessions des terres et des eaux maritimes du Cambodge à la République Socialiste du Vietnam ;

4. **Demandons** aux Députés cambodgiens d'engager immédiatement une procédure de Déclaration par l'Assemblée Nationale de la NON-RECONNAISSANCE de ces traités et accords de 1979, 1982, 1983, 1985, entre la RSV et la RPK et tous leurs effets, conformément aux Accords de Paix de Paris de 1991 sur le Cambodge et à l'Article 55 de la Constitution du Royaume du Cambodge ;

5. **Demandons** au Président de l'Assemblée Nationale, le prince Norodom Ranariddh, en vertu des articles 55 et 92 de la Constitution du Royaume, d'opposer une exception d'irrecevabilité au projet de «Traité additif» élaboré sur des bases illégales par le Gouvernement royal et le Gouvernement de la République Socialiste du Vietnam ;

6. **Prions** très respectueusement Sa Majesté le Roi Preah Bat Norodom Sihanouk de daigner veiller à l'application stricte par le Gouvernement royal et le Parlement du Cambodge des Accords de Paris de 1991 et des dispositions péremptoires de la Constitution du Royaume ;

7. **Soutenons** avec une profonde admiration et une grande fierté la Haute et patriotique décision de Sa Majesté le Roi de ne pas reconnaître, comme par le passé, les Traités et Accords illégaux entre la République Socialiste du Vietnam et la dénommée République Populaire du Kampuchéa, ni, aujourd'hui, le projet de «Traité additif» élaboré par le Gouvernement actuel de M. Hun Sèn avec la République Socialiste du Vietnam ;

8. **Prions** le Secrétaire Général de l'Organisation des Nations Unies, ainsi que les Gouvernements de la France et de l'Indonésie, Co-Présidents de la Conférence de Paix de Paris de 1991, de bien vouloir rappeler aux Gouvernements signataires des Accords issus de cette Conférence, en particulier le Vietnam, la Thaïlande et le Cambodge, leurs engagements de respecter l'intégrité et l'inviolabilité territoriales du Cambodge, ainsi que l'engagement du Cambodge de mettre fin à ces traités et accords entre la RSV et la RPK absolument incompatibles avec sa souveraineté, son indépendance, sa neutralité, son intégrité et son inviolabilité territoriales, et son unité nationale.

---

Le président du Comité des Frontières du Cambodge est chargé de soumettre la présente Résolution à la Haute connaissance de Sa Majesté le Roi NORODOM SIHANOUK,
et de la transmettre, pour suites de droit,
- au Prince Norodom Ranariddh, Président de l'Assemblée nationale,
- au Président et aux Membres de l'Assemblée nationale et du Sénat,
- au Président et aux Membres du Conseil Constitutionnel,
- à Monsieur HUN SEN, Premier Ministre,
- à Monsieur Le Secrétaire Général de l'ONU,
- à Madame et Monsieur Les Co-Présidents de la Conférence de Paris sur le Cambodge,
- au Gouvernement de la République Socialiste du Vietnam et au Gouvernement du Royaume de Thaïlande,
- aux Gouvernements des autres Etats signataires des Accords de Paris sur le Cambodge.
- FAIT À PARIS (FRANCE), LE 23 FEVRIER 2003

Le Président
de l'Association «Les Jeunes Khmers»,

*(Signature) VORGN BORIN*

Le Président
du «Comité des Frontières du Cambodge»,

*(Signature) SEAN PENGSÈ*